ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ១០០/២០ គ.ជ.ប.ជ

# របាយការណ៍ត្រីមាសទី១
# ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនិងទិសដៅអនុវត្តបន្តត្រីមាសទី២ ឆ្នាំ២០២០

## I. ស្ថានភាពទូទៅ

ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាប ជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គភាពពាក់ព័ន្ធនានា រួមទាំងលេខាធិការដ្ឋាន គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ)។ ក្រោយពីកិច្ចខិតខំប្រឹងប្រែងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃ បានសហការគ្នាផ្តល់ភាពស្របច្បាប់ជូនពលករប្រមាណ ជាងមួយលានប្រាំមួយម៉ឺននាក់ ហើយក៏ដោយ ក៏ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍មិនប្រក្រតីក៏នៅតែមានដដែល ពលរដ្ឋខ្មែរនៅតែបាន និងកំពុងចូលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ជាបន្តទៅទៀត ទោះបីត្រូវជួបប្រទះបញ្ហាប្រឈម ហានីភ័យនានា ដូចជា ការបញ្ជូនត្រឡប់មកវិញ ការឃាត់ខ្លួន ការដាក់ទោសទណ្ឌ ពីអាជ្ញាធរប្រទេសថៃ រងការកេងប្រវ័ញ្ច ខាតបង់ប្រាក់កាស និងពេលវេលា ជាដើម។ល។ ប្រជាពលរដ្ឋមួយចំនួន នៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ច ផ្តល់ឯកសារក្លែងក្លាយជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងច្បាប់៖
  - ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA)
  - ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី "ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រី លើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្តីពី "**ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី**"។

ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ ធ្វើសេចក្តីព្រៀងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ**"។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាន៖
  - បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយអង្គការចំនួន ០៥ មានៈ អង្គការសម្ព័ន្ធចាប់ដៃ អង្គការក្តីសង្ឃឹម និងយុត្តិធម៌ អង្គការក្តីស្រឡាញ់គ្មានព្រំដែន អង្គការសង្គ្រោះ និងថែទាំស៊ីធីភញ និង អង្គការសកម្មភាពដើម្បីកុមារ ដោយឯកឧត្តម **តូច ចាន់នី** អគ្គនាយកបច្ចេកទេស នៅថ្ងៃទី ២៤ ខែមករា ឆ្នាំ២០២០។
  - ធ្វើសេចក្តីព្រៀងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

**ខ. ការបង្ការ ទប់ស្កាត់**

**ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង**

ខ.១.១. ការផ្សព្វផ្សាយជាសាធារណៈ

| ល.រ | ផ្សព្វផ្សាយតាមរយៈ | ចំនួនលើក | ចំនួនអ្នកចូលរួម |
|---|---|---|---|
| ១ | វេទិកាសាធារណៈ និងភូមិ-ឃុំមានសុវត្ថិភាព | ២៩.៨៦២ លើក | ១.៦៧៩.៥៧៨ នាក់ |
| ២ | កម្មវិធីផ្សេងៗ | ០៤ លើក | ៥០០ នាក់ |
| ៣ | អង្គការដៃគូនានា | ៣៤ លើក | ២.២៤៦ នាក់ |
| សរុប | | ២៩.៩០០ លើក | ១.៦៨២.៣២៤ នាក់ |

### ខ.១.២.ការអប់រំផ្សព្វផ្សាយដោយផ្ទាល់

នៅក្នុងត្រីមាសទី១ ឆ្នាំ២០២០នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន ២៩.៨៦២លើកមានអ្នកចូលរួមសរុបចំនួន ១.៦៧៩.៥៧៨ នាក់(បើប្រៀបធៀបនឹងត្រីមាសទី១ ឆ្នាំ២០១៩ មានចំនួន ៧៩៧.៥០៨នាក់ គឺមានការកើនឡើងចំនួន ៨៨២.០៧០នាក់ ស្មើនឹង៥២,៥១% ក្នុងនោះស្ត្រីចំនួន ៩០៨.៦៣៨នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

*តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ*

| | ក្រសួង ស្ថាប័ន រាជធានី ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| **ក្រសួង ស្ថាប័ន** | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៤១០ | ១៨.៣៨៤ | ១០.៧៨២ | ០ | ០ | ០ |
| ២ | | ០ | ០ | ០ | ០ | ០ | ០ |
| | **សរុប ក្រសួង ស្ថាប័ន** | ៤១០ | ១៨.៣៨៤ | ១០.៧៨២ | ០ | ០ | ០ |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | ០ | ០ | ០ | ០ | ០ | ០ |
| ២ | ខេត្តកណ្តាល | ១.៦៥៧ | ១០៦.២៥៣ | ៥.៥០០៧ | ៣.៧៨៥ | ២៥២.៥៥៣ | ១៣៣.១៤៧ |
| ៣ | ខេត្តបាត់ដំបង | ៣.៣៤០ | ១៦.៧៧៣១ | ៨៦.៥៦៧ | ២.០០០ | ៥៤.២៧០ | ២៨.៣៨៩ |
| ៤ | ខេត្តពោធិ៍សាត់ | ១.០២៣ | ៨១.៧៤៥ | ៤៥.៦៥៤ | ៣៣៩ | ១៤.២០៤ | ៧.១១៥ |
| ៥ | ខេត្តសៀមរាប | ១.៤០៣ | ៩៤.៥០២ | ៥២.៩៣១ | ២៥២ | ៨.០៦៨ | ២៨.០៣៧ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៣.៥៤២ | ១៩១.៣១៦ | ១០៦.២៨០ | ២.៣៤៥ | ៩៣.៣៧១ | ៤៩.៨២៨ |
| ៧ | ខេត្តកំពង់ចាម | ៤.២៦៥ | ២៧២.២០៥ | ១៣៤.៧០៥ | ១.៣៧៨ | ៧៧.៧៤០ | ៤៣.៥៨៨ |
| ៨ | ខេត្តព្រះសីហនុ | ១៨ | ១.៧៧៥ | ៨៩២ | ៥ | ១៩០ | ៨៣ |
| ៩ | ខេត្តព្រះវិហារ | ១៥៨ | ៤១.០៧៧ | ២១.៥៧៦ | ១២០ | ១១.៥៤១ | ២.៦៥២ |
| ១០ | ខេត្តស្វាយរៀង | ៨ | ៣៤ | ២៥ | ១.០៥២ | ៤៤.២៥៦ | ២៤.៣៩៩ |
| ១១ | ខេត្តប៉ៃលិន | ២៨៥ | ៧.៩១៦ | ៤.៦៨៧ | ៧៨ | ៥.៨៦៣ | ២.៦៧៩ |
| ១២ | ខេត្តកោះកុង | ១០ | ៣៦៤ | ១០៦ | ៤៤៨ | ១៤.២០១ | ៧.៥៩៥ |
| ១៣ | ខេត្តកំពត | ១៥ | ៩៩៨ | ៣៩៩ | ១០ | ៧៥៣ | ៥៣៣ |
| ១៤ | ខេត្តកំពង់ធំ | ១ | ២៩៨ | ១៥៩ | ០ | ០ | ០ |
| ១៥ | ខេត្តតាកែវ | ៩៣២ | ៥១.៦១៩ | ២៥.០៨១ | ៣១៨ | ១៣.០៧៨ | ១០.៣៣៦ |
| ១៦ | ខេត្តក្រចេះ | ១៤ | ៦៨៦ | ៤២៧ | ៤ | ៦០៦ | ១៣៤ |
| ១៧ | ខេត្តកែប | ៤៦ | ៨.១៦០ | ១.១៩២ | ៣៧ | ១១.២៦២ | ៥.៦៩១ |
| ១៨ | ខេត្តកំពង់ស្ពឺ | ៤៧០ | ២៣.៣៣០ | ១០.៩៩៩ | ៨៤ | ២.៣២៤ | ១.៣២៤ |
| ១៩ | ខេត្តស្ទឹងត្រែង | ០ | ០ | ០ | ០ | ០ | ០ |
| ២០ | ខេត្តរតនគិរី | ០ | ០ | ០ | ០ | ០ | ០ |
| ២១ | ខេត្តព្រៃវែង | ១ | ៤៥០ | ០ | ០ | ០ | ០ |
| ២២ | ខេត្តត្បូងឃ្មុំ | ៨ | ៦២២៥ | ៥.៦០៤ | ០ | ០ | ០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២៣ | ខេត្តបន្ទាយមានជ័យ | ០ | ០ | ០ | ០ | ០ | ០ |
| ២៤ | ខេត្តឧត្តរមានជ័យ | ០ | ០ | ០ | ០ | ០ | ០ |
| ២៥ | ខេត្តមណ្ឌលគិរី | ០ | ០ | ០ | ១ | ២៣០ | ៣៥ |
| សរុប រាជធានី ខេត្ត | | ១៧.១៩៦ | ១.០៥៦.៦៨៤ | ៥៥.៧២៩១ | ១២.២៥៦ | ៦០៤.៥១០ | ៣៨៥.៥៦៥ |
| សរុបរួម | | ចំនួន ២៩.៨៦២លើក | | ចំនួនអ្នកចូលរួម ១.៦៧៩.៥៧៨នាក់ | | ចំនួនស្ត្រី ៩០៨.៦៣៨នាក់ | |

### ខ.១.៣. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- **ថ្នាក់ជាតិ**
  - អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

    ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ APLE បើកកម្មវិធីយុទ្ធនាការ ស្តីពីការលើកកម្ពស់សុវត្ថិភាពអ៊ីនធឺណិត សីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅវិទ្យាស្ថានអប់រំ អ្នកចូលរួមមាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងតំណាងអង្គការជាតិ អន្តរជាតិ សរុបប្រមាណ ៥០០នាក់។
- **ថ្នាក់ក្រោមជាតិ**
  - ខេត្តក្រចេះ៖ មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយនាទីព្រះពុទ្ធសាសនាជាធម្មទានអប់រំផ្លូវចិត្តដើម្បីទប់ស្កាត់នូវការជួញដូរមនុស្ស និងកេងប្រវ័ញ្ចកម្លាំងកុមារ ក៏ដូចយុវជនបាន៣លើក
  - អង្គការដៃគូ

*តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំនានា របស់អង្គការដៃគូ*

| អង្គការ | សកម្មភាព | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
|---|---|---|---|---|
| GVC,អង្គការសាម៉ារីតាន់ភីស អង្គការវីវើល/ជវីស៊ី (ខេត្តបាត់ដំបង) | - ផ្តល់ការអប់រំផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់ពលករចំណាកស្រុក នៅឃុំចំនួន០៣ ក្នុងស្រុកសំឡូត។ | ៦ | ៩៦ | ៨៦ |
| | - បានផ្សព្វផ្សាយអប់រំអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ជនចំណាកស្រុក។ | ១ | ៦២ | ២៣ |
| | - បានសហការជាមួយក្រុមប្រឹក្សាឃុំ និងភូមិគោលដៅ ក្នុងស្រុកសំឡូត ផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព សិទ្ធិការងាររបស់ពលករចំណាកស្រុកក្នុងប្រទេសថៃ និងការទប់ស្កាត់នៃការជួញដូរមនុស្ស។ | ១ | ៩៣ | ៨៨ |
| | - បានសហការជាមួយក្រុមប្រឹក្សាឃុំ និងភូមិគោលដៅ ក្នុងស្រុកសំឡូត ផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព សិទ្ធិការងាររបស់ពលករចំណាកស្រុកក្នុងប្រទេសថៃ និងការទប់ស្កាត់នៃការជួញដូរមនុស្ស ចំនួន៣ឃុំ។ | ១ | ១០១ | ៧៦ |
| វីវើល/ជីវីស៊ី (ខេត្តសៀមរាប) | - បានសហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុក សិទ្ធិការងាររបស់ពលករចំណាកស្រុកក្នុងប្រទេសថៃ និងការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់អាជ្ញាធរមូលដ្ឋាន នៅស្រុកជី | ៥ | ១៧៣ | ១២៧ |

| | | | | |
|---|---|---|---|---|
| | ក្រែង។ | | | |
| អង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី (ខេត្តកោះកុង) | - បានផ្សព្វផ្សាយ ស្តីពី ប្រការគួរយល់ដឹងមុនសំរេចចិត្តចំណាកស្រុកទៅក្រៅប្រទេស ក្នុងសហគមន៍ចំនួន០៤។ | ៤ | ៨២ | ៦៤ |
| | - បានចូលរួមចំណែកក្នុងការអនុវត្តបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈការពង្រឹងសមត្ថភាពសហគមន៍ ការផ្តល់ប្រឹក្សាពិគ្រោះយោបល់ លើការចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពរួមមាន៖ ការប្រជុំក្រុមជួយខ្លួនឯងប្រចាំខែលើប្រធានបទយល់ដឹងពីលិខិតឆ្លងដែនកម្ពុជា។ | ៥ | ១១៧ | ៩០ |
| សាម៉ារីតាន់ភឺស (ខេត្តបន្ទាយមានជ័យ) | - បានអប់រំផ្សព្វផ្សាយស និងចែកខិត្តប័ណ្ណស្តីពី ការធ្វើចំណាកស្រុក ដោយសុវត្ថិភាព។ | ២ | ៩៤៥ | ៣៨៨ |
| អង្គការការលើកាដូ និងអង្គការអាដហុក (ខេត្តតាកែវ) | - បានធ្វើការផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋនៅស្រុកទឹកឈូក។ | ១ | ៣៧ | ២៣ |
| អង្គការឆាលហ្វាន់ និង CCPCR (ខេត្តស្វាយរៀង) | - ផ្សព្វផ្សាយអំពីបញ្ហាប្រឈមងាយរងគ្រោះដោយការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព ការរំលោភបំពាន ការកេងប្រវ័ញ្ច និងកិច្ចការពារកុមារ នៅឃុំក្រសាំង និងឃុំអណ្តូងត្របែក ស្រុករមាសហែក។ | ២ | ២៣១ | ១០៣ |
| | - ផ្សព្វផ្សាយអំពីបញ្ហាប្រឈម និងងាយរងគ្រោះដោយការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព ការរំលោភបំពាន ការកេងប្រវ័ញ្ច និងកិច្ចការពារកុមារ នៅឃុំក្រសាំង និងឃុំអណ្តូងត្របែក ស្រុករមាសហែក។ | ៣ | ១៧៥ | ៣៩ |
| | - ផ្សព្វផ្សាយអំពីបញ្ហាប្រឈម និងងាយរងគ្រោះដោយការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព ការរំលោភបំពាន ការកេងប្រវ័ញ្ច និងកិច្ចការពារកុមារ នៅឃុំក្រសាំង និងឃុំអណ្តូងត្របែក ស្រុករមាសហែក។ | ៣ | ១៣៤ | ៧៨ |
| សរុប | | ៣៤ លើក | ២.២៤៦ នាក់ | ១.១៨៥ នាក់ |

### ខ.១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិកត្រូនិក

- **ខេត្តសៀមរាប៖**
  - មន្ទីរព័ត៌មានខេត្ត បានសហការជាមួយអង្គភាព អាជ្ញាធរ និងអង្គការពាក់ព័ន្ធ ធ្វើកម្មវិធី "យើងធ្វើបាន" និង "សន្ទនាមតិ" ដោយផ្សាយផ្ទាល់ ០៦លើក ចាក់ផ្សាយឡើងវិញ ១៨លើក និងផ្សព្វផ្សាយស្ពតអប់រំសរុប ២.៨៧៤លើក។
  - មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុ FM ជាតិនគរភ្នំ ១០៣ MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប អំពីអំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ពិសេសការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិល និងការផ្សព្វផ្សាយអំពីស្ពតអប់រំ ស្តីពីគ្រឿងញៀន ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងពាក់ព័ន្ធការជួញដូរមនុស្ស សរុបចំនួន ២.៩២៥លើក (ផ្សាយផ្ទាល់ ១២លើក ចាក់ផ្សាយឡើងវិញ ៦៦លើក និងផ្សព្វផ្សាយស្ពត ២.៨៧៧លើក)។

- ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងការផ្សព្វផ្សាយ នៅប៉ុស្តិ៍វិទ្យុជាតិនគរភ្នំខេត្តសៀមរាប ស្តីពីការអន្តរាគមន៍ជួយសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ០១លើក។

- ខេត្តតាកែវៈ ផ្សព្វផ្សាយព័ត៌មាន ស្តីពីច្បាប់ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុគោគធ្លក បានចំនួន ៣០អត្ថបទ និង ៤២លើក។
- ខេត្តក្រចេះៈ មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុ FM .៩៨.៥ ស្តីពីច្បាប់ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចំនួន ០៥លើក។
- ខេត្តកំពង់ចាមៈ មន្ទីរព័ត៌មានខេត្តបានផ្សព្វផ្សាយតាមរយៈវិទ្យុជាតិភ្នំប្រុស ពាក់ព័ន្ធនឹងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ចំនួន ០៣លើក រយៈពេល៣ម៉ោង។

**១.១.៣. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា**

- ខេត្តក្រចេះៈ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារក្រោមប្រធានបទ អំពើហិង្សា និងការរំលោភសេសន្លវៈលើស្ត្រី និងកុមារ តាមរយៈការផ្សព្វផ្សាយសម្លេង និងការឡាយតាមផេកហ្វេកប៊ុក របស់វិទ្យុសម្លេងស្ត្រីខេត្ត ចំនួន ០៣លើក។
- **ខេត្តកំពង់ចាមៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត**
  - បានចូលរួមជាគ្រូឧទ្ទេសធ្វើបទបង្ហាញ ស្តីពីនីតិវិធីទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស ចំនួន ០២លើក នៅសាលាស្រុកព្រៃឈរ និងស្រុកចំការលើ ខេត្តកំពង់ចាម។
  - បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទាមតិ ក្រោមប្រធានបទ សុវត្ថិភាពនៃការធ្វើចំណាកស្រុកដោយមិនស្របច្បាប់នៅវិទ្យុជាតិភ្នំស្រី ភ្នំប្រុស ខេត្តកំពង់ចាម ចំនួន ០១លើក។

## ១.២. ការបង្ការ ទប់ស្កាត់ តាមមិធានការជំនាញ

### ១.២.១. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
  - បានចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅមណ្ឌលអង្គការHope For Justic អង្គការសួននៃក្តីសង្ឃឹម អង្គការមេត្រីអន្តរជាតិ(AIM) និងអង្គការរតនៈអន្តរជាតិ។
  - បានចុះត្រួតពិនិត្យគម្រោងរបស់អង្គការដែលបានសុំបន្តកិច្ចព្រមព្រៀងជាមួយក្រសួង ស.អ.យរយៈពេល ៣ឆ្នាំទៀត រួមមានៈ អង្គការមូលនិធិហាកាអន្តរជាតិ និងអង្គការពន្លកថ្មីដែលមានទីតាំងនៅរាជធានីភ្នំពេញ និងខេត្តសៀមរាប។
  - បានធ្វើការចុះប៉ាន់ប្រម៉ាណគ្រួសារ និងកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សបណ្តោះអាសន្នចំនួន ០២លើក សរុបចំនួនមនុស្ស ០៧នាក់ (ស្រី ០១នាក់ ដូចជាមាននៅៈ ស្រុកប្រសាទសំបូរ ខេត្តកំពង់ធំ ០៦នាក់ (ករណីជួញដូរកម្លាំងពលកម្ម) និងស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ០១នាក់ (ករណីអាពាហ៍ ពិពាហ៍ផ្ទុងពីធន្ទះ/បង្ខំ)។
  - មន្ត្រីនៃនាយកដ្ឋាន ស.អ.យ បានចុះពិនិត្យ និងពិភាក្សាការងារជាមួយមន្ត្រីទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលកំពង់ធ្វើសកម្មភាពទទួល និងបញ្ជូនជនរងគ្រោះ និងជនងាយរងគ្រោះទៅសហគមន៍វិញ នៅខេត្តកោះកុង។
- **ខេត្តកំពង់ស្ពឺ**
  - ក្រុមការងារអធិការកិច្ចរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ និងបានបញ្ជ្រាបអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមបណ្តាក្រុមហ៊ុននានាចំនួន ០២លើក។

- ខេត្តប៉ៃលិនៈ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ នៅតាមគ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សែវ្ទូ កាស៊ីណូ ឡូតជួ និងអាហារដ្ឋាន ចំនួន ៨០កន្លែង។
- ខេត្តកំពង់ធំៈ ស្នងការដ្ឋាននគរបាលជាតិ បានបិទប្រកាសសេចក្តីណែនាំ ដើម្បីផ្សព្វផ្សាយច្បាប់បង្ការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារបានចំនួន ៣០២សន្លឹក តាមបណ្តាគោលដៅអាជីវកម្ម ដូចជាៈ ខារ៉ាអូខេ ក្លឹបកម្សាន្ត សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល កន្លែងកោសជប់ និងភោជនីយដ្ឋាន បានចំនួន ៩១កន្លែង។

## ខ.២.២. ការគ្រប់គ្រងស្ថិតិៈ បច្ចុប្បន្នភាពចំណាកស្រុក

- អគ្គស្នងការដ្ឋាននគរបាលជាតិ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានធ្វើបច្ចុប្បន្នភាពលើទិន្នន័យពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅក្រៅប្រទេស ប្រចាំខែនីមួយៗ បានពិនិត្យឃើញថា នៅតែបន្តកើតមានឡើង ជាក់ស្តែងត្រីមាសទី១ ឆ្នាំ២០២០៖

*តារាងតាមដានបច្ចុប្បន្នភាពលើទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុក*

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | |
| មករា | ៣៣៣.៤៩២ | ១៤៩.៤១៥ | ៦.៤៧៨ | ២.៦០៤ | ២១២.៣៦៨ | ១០១.០៦៧ | ១៧.៤០ | ៧២៤ | ១២១.១២៤ | ៤៨.៣៤៨ | ៤.៧៣៨ | ១.៨៨០ | ថយចុះ ២៤.២៩៩ |
| កុម្ភៈ | ៣៣៣.៩៦០ | ១៤៨.៣៦៣ | ៦.១១០ | ២.៤៧៥ | ២១២.២២៦ | ៩៩.៨២១ | ១.៦០៩ | ៦៨៣ | ១២០.៨៧០ | ៤៨.៥៤២ | ៤.៥០១ | ១.៧៩២ | ថយចុះ ៣៩៦ |
| មីនា | ៣១៥.៥០៦ | ១៩៦.៦១៣ | ៥.២៣៨ | ២.០៥៧ | ២១៥.១៤២ | ១៤៧.៩៩៣ | ៧០១ | ២៧៩ | ១០០.៣៦៤ | ៤៨.៦២០ | ៤.៥៣៧ | ១.៧៧៨ | កើនឡើង ១៣.៥៩០ |

- ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបងៈ កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរនគរបាលការពារព្រំដែនគោកវរសេនាតូចលេខ ៨១៧ ៨១៩ ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួនបានចំនួន ២១១លើក ពុំបានប្រទះឃើញពលករឆ្លងដែនខុសច្បាប់ទេ។

- ខេត្តកំពង់ធំៈ ស្នងការដ្ឋាននគរបាលខេត្ត បានចុះធ្វើបច្ចុប្បន្នភាព និងផ្សព្វផ្សាយច្បាប់បង្ការ បង្ក្រាប និងធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ តាមបណ្តាលគោលដៅអាជីវកម្មខារ៉ាអូខេ ក្លឹបកម្សាន្ត សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល កន្លែងកោសជប់ និងភោជនីយដ្ឋាន អ្នកចូលរួមចំនួន ៥០៨នាក់ (ស្រី ៤៥៥នាក់) ព្រមទាំងបានបិទសេចក្តីណែនាំបានចំនួន ៩១កន្លែង ស្មើនឹង ៣០២សន្លឹក។

## ខ.២.៣. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- អគ្គស្នងការដ្ឋាននគរបាលជាតិ
  - ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ សរុបចំនួន ៧៥គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ៦៦គោលដៅ។
  - ស្នងការដ្ឋាននគរបាលខេត្តតាកែវ កែប ស្វាយរៀង ព្រៃវែង កំពង់ធំ ក្រចេះ មណ្ឌលគិរី និងខេត្តរតនគិរី បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើស

សញ្ជារកម្ម និងផ្សព្វផ្សាយ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្មស្ត្រីក្នុងហាងម៉ាស្សា ខារ៉ាអូខេ ដែលមានតារាងដូចខាងក្រោម៖

តារាងបច្ចុប្បន្នភាពគោលដៅសេវាកម្សាន្ត ដែលបានធ្វើការអប់រំដើម្បីបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងត្រីមាសទី១ ឆ្នាំ២០២០

| ត្រីមាសទី១ ឆ្នាំ២០២០ | | | |
|---|---|---|---|
| បរិយាយ | ខែមករា | ខែកុម្ភៈ | ខែមីនា |
| ចំនួនគោលដៅ | ៥០៨គោលដៅ | ៦១៩ គោលដៅ | ៦៣០ គោលដៅ |
| ចំនួនមនុស្ស | ២.១២៧នាក់ | ៧.២៨៩ នាក់ | ៩.៧១៩ នាក់ |
| ចំនួនស្ត្រី | ១.៦០៨នាក់ | ៥.៣៧២ នាក់ | ៦.០៧៣ នាក់ |

- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ ក្រចេះ សៀមរាបនិងខេត្តព្រះវិហារ ល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន ១១០លើក។

**ខ.២.៤. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

▪ ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) នៃច្រកចេញចូលតែមួយ របស់ក្រសួងមហាផ្ទៃទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន ៥២០គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅ នារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេស តាមរយៈទូរស័ព្ទផ្ទាល់ ចំនួន ៥០នាក់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្ស តាមរយៈការរៀបអាពាហ៍ពិពាហ៍។

**ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- ខេត្តសៀមរាប៖
  - **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត** ចុះអធិការកិច្ចការងារ និងវិធានការចំពោះសហគ្រាសដែលប្រព្រឹត្តល្មើសច្បាប់ ស្តីពីការងាររួមមាន៖ អធិការកិច្ចសាមញ្ញបានចំនួន ០៧សហគ្រាស និងអធិការកិច្ចក្រៅកម្មវិធីបានចំនួន ០៣សហគ្រាស។
  - **ក្រុមការងារចម្រុះលេខាធិការដ្ឋាន** រួមមានក្រុមការងារបង្ការ ទប់ស្កាត់ ក្រុមការងារកិច្ចការអនុវត្តច្បាប់ ក្រុមការងារកិច្ចការការពារជនរងគ្រោះ ក្រុមការងារកិច្ចការទេសន្តរប្រវេសន៍ ទីចាត់ការអន្តរវិស័យសាលាខេត្ត រដ្ឋបាលក្រុង នាយប៉ុស្តិ៍ បានចុះត្រួតពិនិត្យមណ្ឌលថែទាំកុមារដារ៉ូម៉ា ដើម្បីធ្វើការត្រួតពិនិត្យលើ៖ ១.មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ចុះត្រួតពិនិត្យលើបទដ្ឋានអប្បបរិមា នៃការថែទាំកុមារជំនួសក្នុងមណ្ឌល។ ២.មន្ទអប់រំ យុវជន និងកីឡាខេត្ត ចុះត្រួតពិនិត្យ លើការសិក្សាតាមស្តង់ដារបស់កុមារ ដែលកំពង់ស្នាក់នៅក្នុងមណ្ឌលអង្គការ។ ៣.ការអនុវត្តច្បាប់ ស្តីពីបែបបទ នៃការសុំចុះបញ្ជីអនុវត្តសកម្មភាពប្រទេសអ្វី។
  - **មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត** ចុះអធិការកិច្ចការងារ និងវិធានការចំពោះសហគ្រាសដែលប្រព្រឹត្តល្មើសច្បាប់ ស្តីពីការងាររួមមាន៖ អធិការកិច្ចសាមញ្ញបានចំនួន ១២សហគ្រាស និងអធិការកិច្ចក្រៅកម្មវិធីបានចំនួន ០១សហគ្រាស។
- **ខេត្តព្រះសីហនុ៖** សហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញដែលបានដាក់ចំនួន ១.១៣៣នាក់ (ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍)។

- **ខេត្តប៉ៃលិន៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ នៅតាមគ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សៃឡូ កាស៊ីណូ ឡូតដ្ឋ និងអាហារដ្ឋាន ចំនួន ៨០កន្លែង។
- **ខេត្តក្រចេះ៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានចុះត្រួតពិនិត្យមណ្ឌលអង្គការដំណឹងល្អចំនួន ០៤ មានកុមារ ចំនួន **១៧**នាក់ (កុមារី ០៥នាក់)។ និងបានសហការជាមួយអង្គការភូមិកុមារកម្ពុជា SOS ប្រចាំខេត្តក្រចេះ ទទួលកុមារកំព្រាឲ្យមករស់នៅក្នុងអង្គការ បានសរុបចំនួន ៩៥នាក់ (ស្រី ៤១នាក់)។
- **ខេត្តកំពង់ធំ៖** បានចុះត្រួតពិនិត្យការងារក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារបានចំនួន ២១សាលា អ្នកចូលរួមចំនួន ៣៥៨នាក់ (ស្រី **១៧៥**នាក់)។

**ខ.៤. ការកាត់បន្ថយភាពងាយរងគ្រោះ តាមរយៈការផ្តល់ប័ណ្ណព្រំដែនដល់មុខសញ្ញាងាយរងគ្រោះ**

- រដ្ឋបាលខេត្តចំនួន០៣ គឺខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន ១៩.៨៤៣ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មាន:

  - ខេត្តបាត់ដំបង ចំនួន ១០.៥៣៧ប័ណ្ណ
  - ខេត្តបន្ទាយមានជ័យ ចំនួន ៤.៤៣៤ប័ណ្ណ
  - ខេត្តប៉ៃលិន ចំនួន ៤.៨៧២ប័ណ្ណ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ កណ្តាល និងខេត្តព្រៃវែង។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ២៧ករណី/៤២ករណី (ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៩ ថយចុះចំនួន ១៥ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៣១នាក់/៥៥នាក់ (ស្រី ០៨នាក់) អនីតិជន ០២នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន **១០៧**នាក់/**១៥៧**នាក់ មាន: អាយុក្រោម១៥ឆ្នាំ **២២**នាក់ អាយុ១៥-១៧ឆ្នាំ **១២**នាក់ និងអាយុពី១៨ឆ្នាំឡើង **៧៣**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច **៣៤**នាក់ និងប្រគល់ឲ្យគ្រួសារ **៧៣**នាក់) ក្នុងនោះមានចែកជា៖

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០៧ករណី/០៤ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០៩នាក់(ស្រី ០៥នាក់) និងសង្គ្រោះជនរងគ្រោះចំនួន ៦៣នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ ០៥នាក់ អាយុ១៥-១៧ឆ្នាំ ០៣នាក់ និងអាយុពី ១៨ឆ្នាំឡើង ៥៥នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច ០៦នាក់ និងប្រគល់ឱ្យគ្រួសារ ៥៧នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០២ | ០១ | ០៣ |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០៦ | ០១ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន | ០២ | ៥៤ | ០២ |

| | | | |
|---|---|---|---|
| -ការទិញពេស្យាចារកុមារ | ០២ | ០២ | ០៣ |
| *សរុប* | *០៧ ករណី* | *៦៣ នាក់* | *០៩ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ២០ករណី/៣៨ករណី(ថយចុះ ១៨ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ២២នាក់ (ស្រី ០៣នាក់ អនីតិជន ០២នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ៤៤នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១៧នាក់ អាយុ ១៥-១៧ឆ្នាំ ០៩នាក់ និងអាយុពី១៨ឆ្នាំឡើង ១៨នាក់ (ប្រគល់ទៅមន្ទីរសង្គមកិច្ច ២៨នាក់ និងប្រគល់ឲ្យគ្រួសារ ១៦នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -សញ្ចារកម្ម(មានអនីតិជន) | ០១ | ០៦ | ០១ |
| -សញ្ចារកម្ម(ទាក់ទងនឹងពេស្យាចារកុមារ) | ០៣ | ២២ | ០៥ |
| -រូបភាព និងសម្ភារៈអាសអាភាស | ០១ | ០១ | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១១ | ១១ | ១១ (អនី.០២) |
| -អំពើអាសប្រទាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៤ | ០៤ | ០៤ |
| *សរុប* | *២០ ករណី* | *៤៤ នាក់* | *២២ នាក់* |

## គ.២. កិច្ចការយុត្តិធម៌

គ.១.លទ្ធផលចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ ដូចមានក្នុងតារាងលម្អិតខាងក្រោមៈ

១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់អយ្យការអមសាលាដំបូង*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| សរុប | ៥ | ២៤ | ៤ | ៣៨ | ៤៨ | ១០ | ០ | ០ | ៣០ | ០ | ២១ |
| ៥១ | ២៩ នាក់ | | ៤២ នាក់ | | ៥៨ នាក់ | | ០ នាក់ | | ៥១ ករណី | | |

២ .ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត ៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមស៊ើបសួរស្សេះ*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | នៅក្នុងឃុំ | | | | នៅក្រៅឃុំ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ជូនទៅជំនុំជម្រះ | លើកលែង | កំពុងចាត់ការ |
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | | | |
| សរុប | ២ | ២៦ | ៤ | ៣១ | ៤៣ | ៦ | ៧ | ០ | ៤៣ | ៦ | ០ | ០ | ០ | ០ | ៧ | ០ | ១៨ | ០ | ២៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤៥ | ២៨នាក់ | ៣៥ នាក់ | ៤៩ នាក់ | ៧ នាក់ | ៤៩ នាក់ | ៧ នាក់ | ៤៥ ករណី |

### ៣ .ដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមជំនុំជម្រះ*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជជាប់ចោទ | | | ប្រភេទចំណាត់ការ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | | | ទោសព្យួរ | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | ចាត់ការរួច | ផ្តន្ទាទោស ពន្ធនាគារ | | កំពុងចាត់ការ |
| | | | | | | | | | | | | ក្នុងឃុំ | ក្រៅឃុំ | |
| | ប | ស | ប | ស | ប | ស | | | | | | | | |
| សរុប | ២ | ១១ | ៤ | ៣១ | ៣៧ | ១១ | ០ | ០ | ០ | ០ | ១៥ ករណី | ៤៨នាក់ | ០នាក់ | ២៤ករណី |
| ៣៩ | ១៣ នាក់ | | ៣៥ នាក់ | | ៤៨ នាក់ | | | | | | | | | |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន ( ផ្លូវគោក និង ផ្លូវអាកាស ) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ និងការទទួលសាកសព

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែរសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការដៃគូ សរុបចំនួន ៦.៧៥៥នាក់ (ស្រី ២.៩៦៨នាក់) ក្នុងនោះមកពី៖

- ប្រទេសថៃ ចំនួន ៦.៧២១នាក់ ស្រីចំនួន ២.៩៥០នាក់
- ប្រទេសចិន ចំនួន ០៤នាក់ ស្រីចំនួន ០៤នាក់
- ប្រទេសម៉ាឡេស៊ី ចំនួន ២៦នាក់ ស្រីចំនួន ១២នាក់
- ប្រទេសឥណ្ឌូនេស៊ី ចំនួន ០៣នាក់ ស្រីចំនួន ០១នាក់
- ប្រទេសសឹង្ហបុរី ចំនួន ០១នាក់ ស្រីចំនួន ០១នាក់។

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រុមការងារការពារជនរងគ្រោះ សហការជាអង្គការនានា បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស៖

• បានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា ចំនួន ៤៦នាក់(ស្ត្រី ១៨នាក់ កុមារ ០៨នាក់) ក្នុងនោះមកពីប្រទេសម៉ាឡេស៊ី ០២នាក់ ឥណ្ឌូនេស៊ី ០៣នាក់ ថៃ ៣៧នាក់ និងចិន ០៤នាក់ រួមមាន៖

- ប្រលានយន្តហោះអន្តរជាតិភ្នំពេញចំនួន ០៩នាក់(ស្ត្រី ០៧នាក់ ក្នុងនោះមានប្រទេសម៉ាឡេស៊ី ០២នាក់ ឥណ្ឌូនេស៊ី ០៣នាក់ និងចិន ០៤នាក់ *មានករណី(ជួញដូរកម្លាំងពលកម្ម ០៥នាក់ និងអាពាហ៍ពិពាហ៍ដោយផ្ទុយពីឆន្ទៈ/បង្ខំ ០៤នាក់ )*។
- ច្រកអន្តរជាតិប៉ោយប៉ែត(មណ្ឌលសំចតប៉ោយប៉ែត)ចំនួន ២៧នាក់(ស្ត្រី ១១នាក់ កុមារ ០៤នាក់) (ករណីរងគ្រោះដោយអំពើជួញដូរមនុស្ស)។

• មន្ទីរស.អ.យរាជធានី ខេត្ត និងអង្គការដៃគូសរុបចំនួន ៨៤៧នាក់ (ស្រី ៤៣នាក់ កុមារា ៣៤៤នាក់ កុមារី ៤៦០នាក់) ក្នុងនោះមានមន្ទីរស.អ.យរាជធានី ខេត្ត ចំនួន ៥០នាក់(ស្រី ៤៣នាក់ កុមារា ០២នាក់ កុមារី ០៥នាក់) និងអង្គការដៃគូចំនួន ៧៩៧នាក់(កុមារា ៣៤២នាក់ កុមារី ៤៥៥នាក់) មានករណី *(ជួញដូរ*

*មនុស្ស ៩៤នាក់ ជួញដូរផ្លូវភេទ ១៣នាក់ កេងប្រវ័ញ្ចផ្លូវភេទ ៣៦នាក់ រំលោភបំពានផ្លូវភេទ១១៣នាក់ និងករណីងាយរងគ្រោះ ៥៩១នាក់)។*

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
  - នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសពលករខ្មែររងគ្រោះចំនួន ២៨នាក់(ស្រី ២៣នាក់) ដែលត្រឡប់ពីប្រទេសថៃ ០២នាក់ ម៉ាឡេស៊ី ០៤នាក់(ស្រី) ឥណ្ឌូនេស៊ី ០២នាក់ ចិន ២០នាក់(ស្រី១៨នាក់)។
  - តាមការសម្ភាសបានឱ្យដឹងថាទៅតាមរយៈមេខ្យល់ទាំងអស់ ២៥នាក់(ថៃ០២ ចិន២០នាក់ និងម៉ាឡេស៊ី០៣នាក់) និងទៅតាមក្រុមហ៊ុន ០២នាក់(ម៉ាឡេស៊ី ០១ និង ឥណ្ឌូនេស៊ី ០១នាក់) និងទៅដោយខ្លួនឯង ០១នាក់(ឥណ្ឌូនេស៊ី)។
- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ១៤៣លើក មនុស្សចំនួន ១.២៥០នាក់(ស្រី ២៣៣នាក់ កុមារ ១៥៥នាក់)។ ក្នុងនោះតាម៖

- ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ០៧លើក មនុស្សចំនួន ៥៨នាក់ (ស្រី ០៨នាក់)
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ១៣៦លើក មនុស្សចំនួន ១.១៩២នាក់(ស្រី២២៥នាក់) កុមារចំនួន ១៥៥នាក់។

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**

ស្នងការដ្ឋាននគរបាលខេត្ត ចំនួន០៥ បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងវៀតណាមចំនួន ១៦២លើក មនុស្សចំនួន ២.៥០៩នាក់ (ស្រី ៨០៣នាក់ អនីតិជន ២៦៦នាក់) ក្នុងនោះមាន៖

| | | | | |
|---|---|---|---|---|
| - ខេត្តបន្ទាយមានជ័យ | ចំនួន ១២៨លើក | មនុស្សចំនួន | ១.៩៥២នាក់ | (ស្រី ៥៥៦នាក់) |
| | | អនីតិជនចំនួន | ២៣៧នាក់។ | |
| - ខេត្តបាត់ដំបង | ចំនួន ១១លើក | មនុស្សចំនួន | ៥៩នាក់ | (ស្រី ២២នាក់) |
| | | អនីតិជន | ០១នាក់។ | |
| - ខេត្តកោះកុង | ចំនួន ១៧លើក | មនុស្សចំនួន | ៤២នាក់ | (ស្រី ០៩នាក់) |
| - ខេត្តប៉ៃលិន | ចំនួន ០៣លើក | មនុស្សចំនួន | ៤១៧នាក់ | (ស្រី ១៩១នាក់) |
| | | អនីតិជនចំនួន | ០១នាក់។ | |
| - ខេត្តស្វាយរៀង | ចំនួន ០២លើក | មនុស្សចំនួន | ៣៩នាក់ | (ស្រី ២៥នាក់) |
| | | អនីតិជន | ២៧នាក់។ | |

**ឃ.១.២. ការទទួលសាកសពបញ្ជូនត្រឡប់**

- ខេត្តបាត់ដំបង អាជ្ញាធរថៃបានបញ្ជូនសាកសពពលរដ្ឋខ្មែរមកកម្ពុជាវិញ ដែលស្លាប់ដោយសារគ្រោះថ្នាក់ផ្សេងៗ តាមច្រកទ្វារអន្តរជាតិដូងសរុបចំនួន ០៦នាក់ (ស្រី ០៣នាក់)។

**ឃ.២. ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

ក្រុមការងារការពារជនរងគ្រោះ និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន ៣០៤នាក់(ស្ត្រី ៦៤នាក់ កុមារ ២១៨នាក់)ក្នុងនោះ ក្នុងនោះមាន៖

- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត ក្រោយពីបានសម្ភាសន៍ និងកំណត់អត្តសញ្ញាណរួច បានផ្តល់សេវាស្នាក់នៅរយៈពេលខ្លី និងស្តារនីតិសម្បទា ដល់ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ៦៧នាក់(ស្ត្រី ១៨នាក់ កុមារ ២៧នាក់) និងបានបញ្ជូនទៅអង្គការតំណក់ទឹក អង្គការសាម៉ារីតាន់ភឺស អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) និងអង្គការក្តីសង្ឃឹម និងយុត្តិធម៌ (Hop for Justice)ដើម្បីទទួលសេវាស្នាក់នៅ និងមានការអប់រំ ណែនាំ និងផ្តល់សេវាផ្សេងៗទៀតមុនពេលធ្វើសមាហរណកម្មត្រឡប់ទៅផ្ទះវិញ។
- មន្ទីរសង្គមកិច្ចរាជធានី ខេត្ត បានសង្គ្រោះ ទទួល ផ្តល់សេវាពិគ្រោះយោបល់ និងបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ២៣៧នាក់(ស្ត្រី ៤៦នាក់ កុមារ ១៩១នាក់) ទៅទទួលសេវាស្តារនីតិសម្បទា បន្តនៅមណ្ឌលរបស់រដ្ឋ និងអង្គការដៃគូ ក្នុងនោះមាន៖ មន្ទីរ ស.អ.យរាជធានីភ្នំពេញ ៤៤នាក់ មន្ទីរស.អ.យខេត្តប៉ៃលិន ០១នាក់ មន្ទីរស.អ.យខេត្តបាត់ដំបង ០៣នាក់ មន្ទីរស.អ.យខេត្តសៀមរាប ០១នាក់ មន្ទីរស.អ.យខេត្តស្វាយរៀង ០១នាក់ អង្គការក្តីស្រឡាញ់គ្មានព្រំដែន ៣១នាក់ អង្គការតំណក់ទឹក ០៩នាក់ អង្គការដៃកម្ពុជា ៩៥នាក់ អង្គការបេសកកម្មពិភពលោក ២០នាក់ អង្គការសង្គ្រោះ និងថែទាំស៊ើជីភញ ១៥នាក់ និងអង្គការ Wol Mobilizetion ១៧នាក់ ក្នុងនោះមានករណី *(ជួញដូរមនុស្ស ៨០នាក់ ជួញដូរផ្លូវភេទ ១៣នាក់ រំលោភបំពានផ្លូវភេទ ៩០នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ២៦នាក់(ករណីជួញដូរមនុស្ស) និង (ករណីងាយរងគ្រោះ ២៥នាក់)*។

### ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សអំពើធ្វើអាជីវកម្មផ្លូវភេទ ឱ្យទៅតាមសហគមន៍វិញ សរុបចំនួន ៧១នាក់ (ស្ត្រី ៣៧នាក់ កុមារ ៣៤នាក់) ក្នុងនោះមានៈ នាយកដ្ឋាន ស.អ.យ ០៥នាក់ មន្ទីរស.អ.យខេត្តស្វាយរៀង ៣៣នាក់ មន្ទីរស.អ.យខេត្តសៀមរាប ០២នាក់ អង្គការរតនៈអ៊ិនធើណេសិនណល ២៩នាក់ និងត្រឡប់ទៅផ្ទះវិញដោយខ្លួនឯង ០២នាក់ មានជាករណី *(អាពាហ៍ពិពាហ៍ដោយផ្ទុយពីឆន្ទៈបង្ខំ ០៤នាក់ ជួញដូរកម្លាំងពលកម្ម ៣៣នាក់ និងជួញដូរផ្លូវភេទ ៣៤នាក់)*។

# III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ក.១. ការងារបណ្តុះបណ្តាល

#### ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

តារាងវគ្គបណ្តុះបណ្តាល

| ល.រ | សកម្មភាព | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | ខេត្តក្រចេះ៖ ស្នងការដ្ឋាននគរបាលខេត្ត បានរៀបចំវគ្គបណ្តុះបណ្តាល | | | |
| | - ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងបច្ចេកទេសសម្ភាសន៍ជនរងគ្រោះដោយអំពើហឹង្សាទាក់ទងនឹងយេនឌ័រ និងការជួញដូរមនុស្ស ដែលរៀបចំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ ឧបត្ថម្ភដោយអង្គការ UN WOMEN។ | ០១ | ៥០ | ៣០ |
| | - ស្តីពីបច្ចេកទេសនៃការប្រមូលព័ត៌មាន ការសម្ភាសន៍ ការកសាងសំណុំរឿង និងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញ រៀបចំដោយអង្គការ ឆាលហ្វាន់កម្ពុជា។ | ០១ | ៣៩ | ០០ |

Pasitha

| | | | | |
|---|---|---|---|---|
| ២ | **ខេត្តកំពង់ឆ្នាំង៖** បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីផែនការចុះអប់រំយុវវ័យនៅតាមសហគមន៍ ឱ្យចូលរួមក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅសាលាស្រុកកំពង់ត្រឡាច។ | ០១ | ២០ | ១៨ |
| ៣ | **ខេត្តកំពង់ធំ៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានសហការជាមួយអង្គការសម្រាលទុក្ខមនុស្សជាតិកម្ពុជា បើកវគ្គ បណ្តុះបណ្តាល ស្តីពីនីតិវិធីនៃការបញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងស្រុកកំពង់ស្វាយ មានចំនួន ០៥ឃុំ គឺឃុំ(ដំរីស្លាប់ នីពេជ ត្បែង សានគរ និងឃុំជ័យ)។ | ០១ | ៨០ | ២៤ |
| ៣ | **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការបន្ទាយស្រី បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងថ្នាក់ស្រុក ថ្នាក់ឃុំ នៅស្រុកអង្គរជុំ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងទប់ស្កាត់អំពើជួញដូរមនុស្ស។ | ០១ | ២៤ | ០៧ |
| | សរុប | ០៤ វគ្គ | ១៩៣ នាក់ | ៥១ នាក់ |

## ក.២. សិក្ខាសាលា

### ក.២.១.សិក្ខាសាលាក្នុងប្រទេស

- ថ្នាក់ជាតិ

  ▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានសហការជាមួយអង្គការ IOM៖

  - រៀបចំសិក្ខាសាលាសម្របសម្រួលថ្នាក់តំបន់លើកទី២ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រទេសបញ្ជូន (កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម) សិក្ខាកាមរួមចំនួន ៦១នាក់ នៅសណ្ឋាគារភ្នំពេញ។
  - រៀបចំសិក្ខាសាលាថ្នាក់ជាតិលើកទី០២ ស្តីពីកតិកាសញ្ញាណសកល សម្រាប់ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព សិក្ខាកាមចូលរួមចំនួន ៣៣នាក់ (ស្រី ១២នាក់) នៅសណ្ឋាគារភ្នំពេញ។
  - រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដាអន្តរទំនាក់ទំនង និងផែនការ សិក្ខាកាមចូលរួមចំនួន ៥២នាក់ (ស្រី ១៣នាក់) នៅភោជនីយដ្ឋានទន្លេបាសាក់២។

  ▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ បានរៀបចំសិក្ខាសាលាចំនួន ០២លើក លើគោលការណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដល់មន្ត្រីសាលាស្រុក មន្ត្រីស.អ.យស្រុក មេឃុំ មេភូមិ មន្ត្រី គ.ក.ន.ក គ្រូបង្រៀន គ្រូពេទ្យ នគរបាលប៉ុស្តិ៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត នៅស្រុកសូទ្រនិគម ខេត្តសៀមរាប និងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មានសិក្ខាកាមចូលរួមសរុបចំនួយ ១១៣នាក់ ស្រី៤៨នាក់។

  ▪ ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រៀបចំសិក្ខាសាលាផ្សព្វផ្សាយផែនការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ២០១៩-២០២៣ នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។

- ថ្នាក់ក្រោមជាតិ

  - ខេត្តកំពង់ស្ពឺ៖ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី **"ការអនុវត្តគម្រោងចំណាកស្រុកឆ្លងដែន"** រៀបចំដោយអង្គការវ៉ៃរ និងឧបត្ថម្ភដោយអង្គការ UN Women ដែលមានសិក្ខាកាមចូលរួមចំនួន ៦២នាក់ (ស្រី ២៤នាក់) នៅសាលាស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។

- ខេត្តព្រះសីហនុ៖ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការអនុវត្តគម្រោងចំណាកស្រុកឆ្លងដែន" រៀបចំដោយអង្គការឃែរ និងឧបត្ថម្ភដោយអង្គការ UN Women ដែលមានសិក្ខាកាមចូលរួមចំនួន ៤៨នាក់ (ស្រី ២៦នាក់) ខេត្តព្រះសីហនុ។

**ក.២.១.សិក្ខាសាលាក្រៅប្រទេស**

- ថ្នាក់ជាតិ

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ បានចូលរួមសិក្ខាសាលាអ្នកគោលការណ៍ណែនាំ និងនីតិវិធីថ្នាក់តំបន់ ដើម្បីដោះស្រាយតម្រូវការរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ ។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. សន្និសីទ កិច្ចប្រជុំ ក្នុងប្រទេស និងក្រៅប្រទេស

➢ **កិច្ចប្រជុំក្នុងប្រទេស**

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)

-លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំកិច្ចប្រជុំ៖

- ពិភាក្សារៀបចំសិក្ខាសាលាសម្របសម្រួលថ្នាក់តំបន់ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រទេសបញ្ជូន (កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម C.L.M.V) ។ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះមាន ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតិតយុទ្ធជន និងយុវនីតិសម្បទា និងតំណាងមកពីក្រសួង ស្ថាប័ន ដៃគូឯកជនជាច្រើនរូប ដែលមានវត្តមានសរុបចំនួន ២៤នាក់ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- ពិភាក្សាត្រួតពិនិត្យរបាយការណ៍ឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានអ្នកចូលរួមចំនួន ១៥នាក់។
- ពិភាក្សា ស្តីពីការពង្រឹងកិច្ចសហការរវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាមួយនឹងដៃគូអភិវឌ្ឍន៍ និងពិធីប្រគល់លិខិតថ្លែងអំណរគុណ ចំពោះកិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាមួយគ.ជ.ប.ជ អស់រយៈកាល៥ឆ្នាំកន្លងមក ដល់សមាគម អង្គការជាតិ អន្តរជាតិ ចំនួន៥៦ ក្រុមហ៊ុនឯកជន ចំនួន៤ នៅភោជនីយដ្ឋានទន្លេបាសាក់២ ភ្នំពេញ។

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំកិច្ចប្រជុំ ស្តីពីការធ្វើបច្ចុប្បន្នភាពលើទម្រង់ទទួល តាមដាន និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលមានអ្នកចូលរួមចំនួន ២៧នាក់ ក្នុងនោះមាន (មន្ត្រីជំនាញមកពីនាយកដ្ឋាន ស.អ.យ និងអង្គការដៃគូពាក់ព័ន្ធ) ធ្វើនៅនាយកដ្ឋាន ស.អ.យ

➢ **កិច្ចប្រជុំក្រៅប្រទេស**

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន **សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពីការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មសារជាថ្មី (TEG-RR) ដែលរៀបចំដោយសហប្រធានអូស្ត្រាលី និងស្រីលង្កា ក្រុមជំនាញបច្ចេកទេសរបស់ Bali Process នៅទីក្រុងកូឡំបូ ប្រទេសស្រីលង្កា។

**ខ.២. ការទទួលជួបពិភាក្សាការងារ**

- គណៈកម្មាធិការជាតិ គ.ជ.ប.ជ
  - លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ បាន៖
    - ទទួលជួបសន្ទនាជាមួយ ទីប្រឹក្សាការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ(ORCHR)ប្រចាំកម្ពុជា ដោយផ្តោតសំខាន់ទៅលើកិច្ចសហប្រតិបត្តិកាជាមួយកម្ពុជា លើបញ្ហាយេនឌ័រ និងសិទ្ធិស្ត្រី រយៈពេលពេញមួយឆ្នាំ។
    - ទទួលជួបពិភាក្សាការងារ ជាមួយតំណាងអង្គការឃែរ (CARE) លើគម្រោងស្រាវជ្រាវស្តីពី ចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រជាពលរដ្ឋ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
    - ទទួលជួបពិភាក្សា និងការចែករំលែកបទពិសោធន៍ការងារ រវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) និងតំណាងអង្គការ IJM Cambodia នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
    - បានទទួលជួបពិភាក្សាការងារជាមួយលោក B.Subba Rao លេខាទី២ តំណាងស្ថានទូតឥណ្ឌាប្រចាំ ប្រទេសកម្ពុជា អំពី MOU (កម្ពុជា-ឥណ្ឌា) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
    - បានដឹកនាំតំណាងគណៈប្រតិភូ ដែលអញ្ជើញមកពីប្រទេសឡាវ មីយ៉ាន់ម៉ា វៀតណាម និងអង្គការ IOM ចូលជួបសំដែងការគួរសមជាមួយ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** ក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ និងរាយការណ៍អំពីលទ្ធផល នៃអង្គសិក្ខាសាលាសម្របសម្រួលថ្នាក់តំបន់ ដែលប្រារព្ធធ្វើអស់រយៈពេលពីរថ្ងៃកន្លងមក ស្តីពី"**ការធ្វើចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រទេសបញ្ជូន**" (កម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម) នៅទីស្តីការក្រសួងមហាផ្ទៃ។
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
  - លោកជំទាវវេជ្ជបណ្ឌិត ឧត្តមសេនីយ៍ឯក ប៊ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ បានទទួលជួបពិក្សាការងារជាមួយក្រុមអ្នកស្រាវជ្រាវមកពីសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា អំពីការសិក្សា ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារនៅក្នុងប្រទេសកម្ពុជា។
- ថ្នាក់ក្រោមជាតិ
- ខេត្តកែប៖ លោកឧត្តមសេនីយ៍ត្រី **បែន តារា** ស្នងការដ្ឋាននគរបាលខេត្ត បានដឹកនាំស្នងការរងទទួលផែនព្រហ្មទណ្ឌ ផែនប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងប្រធានការិយាល័យជំនាញ ជួបពិភាក្សាការងារជាមួយអង្គការ ការពារកុមារ ដែលដឹកនាំដោយលោក **ម៉ាយ ស្មីត** ប្រធានផ្នែកស៊ើបអង្កេតរបស់អង្គការ (CPU) នៅសាលប្រជុំស្នងការដ្ឋាននគរបាលខេត្តកែប។

**ខ.៣. ការងារសម្របសម្រួល**

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ១២០លើក មានអ្នកចូលរួមសរុប ២.២៨៨នាក់ (ស្រី ១.០៩៤នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៤២លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ០៥លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ៧៣លើក។ (ឧបសម្ព័ន្ធ)

## III. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្ស ជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិ ផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការ ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖
- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួន នៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ជាប្រចាំ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។

- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## IV. ទិសដៅត្រីមាសទី២ ឆ្នាំ ២០២០

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ **"គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី"** (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល និងការចុះតាមដានការអនុវត្តគោលនយោបាយ នៅថ្នាក់ក្រោមជាតិ ។

១២. ពង្រឹងសកម្មភាពទទួលពលករ ការស្រាវជ្រាវទិន្នន័យ និងផ្តល់សេវាជូនពលករដែលត្រូវបានបញ្ជូនត្រឡប់ពីអាជ្ញាធរបរទេស និងពលករវិលត្រឡប់វិញនៅតាមច្រកព្រំដែនសំខាន់ៗ ។

ថ្ងៃ.............ខែ..........ឆ្នាំ កុរ ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី..១០..ខែ..........ឆ្នាំ២០២០

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ_ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ១២០លើក) មនុស្សចំនួន ២.២៨៨នាក់ (ស្រី ១.០៩៤នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | គ.ប.ជ.ប សម្របសម្រួល ៤២លើក អ្នកចូលរួមចំនួន ៤៥៥នាក់ (ស្រី ៨២នាក់)<br>▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញៈ<br>- ដឹកនាំគណៈប្រតិភូចុះសួរសុខទុក្ខ និងនាំយកនូវថវិការមួយចំនួនជួយឧបត្ថម្ភ ដល់ប្រជាពលរដ្ឋរងគ្រោះ ព្រមទាំងក្រុមគ្រូពេទ្យដែលប្រចាំការមើលថែជនរងគ្រោះ ដោយគ្រោះថ្នាក់រលំបាក់អគារ៦ជាន់នៅខេត្តកែប ហើយកំពុងសម្រាកព្យាបាលក្នុងមន្ទីរពេទ្យបង្អែកខេត្ត។<br>- អញ្ជើញជាអធិបតីភាព ក្នុងកិច្ចប្រជុំពិភាក្សារបាយការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ ជាមួយអង្គការដៃគូ នៅសាលប្រជុំអគ្គលេខា ធិការដ្ឋាន គ.ជ.ប.ជ មានអ្នកចូលរួមចំនួន ៣៥រូប។<br>- ចូលរួម និងថ្លែងសុន្ទរកថាក្នុងពិធីសម្ពោធជាផ្លូវការនូវគម្រោង Grab for Good គាំទ្រមនុស្សគរថ្លង់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម ទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន។<br>- ជាអធិបតីភាព ក្នុងពិធីប្រកាសសេចក្តីសម្រេចអំពីការកែប្រែសមាសភាពក្រុមការងារយេនឌ័រ របស់លេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ ក្នុងការអនុវត្តតួនាទី ភារកិច្ច នៅទីស្តីការក្រសួងមហាផ្ទៃ អាគារ ទ ។<br>- ចូលរួមក្នុងពិធីផ្សព្វផ្សាយដាក់ឲ្យប្រើប្រាស់នូវក្រមសីលធម៌សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **អិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអនុប្រធានគនិងជាប្រធានក្រុមការងារទេសន្តប្រវេសន៍ នៅសណ្ឋាគារ ជ.ប.ជ.ភ្នំពេញ។<br>- ចូលរួមក្នុងសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **វង់ សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារភ្នំពេញ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួមៈ<br>- បានអមដំណើរ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានចុះសួរសុខទុក្ខប្រជាពលរដ្ឋរងគ្រោះ ដោយរលំអាគារនៅខេត្តកែប ហើយកំពុងសម្រាកព្យាបាលក្នុងមន្ទីរពេទ្យបង្អែកខេត្តកែប ។ |

| | |
|---|---|
| | - កិច្ចប្រជុំពិភាក្សារបាយការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស២០១៩ ជាមួយអង្គការដៃគូក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខា ធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងមានការចូលរួមពី ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង ប្រធាន អនុប្រធានក្រុមជំនួយកិច្ចការទាំង៦ និងតំណាង អង្គការពាក់ព័ន្ធ ដែលមានវត្តមានសរុបចំនួន **៣៥**នាក់ ។<br>- សិក្ខាសាលាស្តីពីវឌ្ឍនភាព នៃការអនុវត្តផែនការយុទ្ធសាស្ត្រទប់ស្កាត់អំពើជួញដូរមនុស្ស និង គ្រោះថ្នាក់បង្កដោយការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ នៅក្រសួងអប់រំយុវជននិងកីឡា ក្រោមអធិបតីភាព ឯកឧត្តម **ស សុខា** រដ្ឋលេខាធិការ ក្រសួងអប់រំយុវជន និងកីឡា មានការអញ្ជើញចូល ពីសំណាក់ ឯកឧត្តម លោកជំទាវ និងមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាច្រើនសរុបរួមមាន **១៦៥**នាក់ ស្រី **២៧**នាក់។<br>- វគ្គ " បណ្តុះបណ្តាលភាពជាថ្នាក់ដឹកនាំសាកល " នៅទីក្រុង Semonoseki ប្រទេសជប៉ុន ។ វគ្គបណ្តុះបណ្តាលនេះ ក៏បានបង្ហាញពីភាពជោគជ័យ បទពិសោធន៍ និងធ្វើការរួមក្រុម ការកសាង អភិបាលកិច្ចល្អ និងការកសាង ទីក្រុង Semonoseki ដោយប្រែក្លាយតំបន់ចំណាកស្រុក ទៅជាតំបន់ អេកូទេសចរណ៍សេដ្ឋកិច្ចការផលិត និងនាំចេញផលិតផលនេសាទ មានសិក្ខាកាមចូលរួមចំនួន **៣៦**នាក់។<br>- កិច្ចប្រជុំពិភាក្សារៀបចំសិក្ខាសាលាសម្របសម្រួលថ្នាក់តំបន់ ស្តីពីការចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រទេសបញ្ចូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV) ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានប្រធានអចិន្ត្រៃយ៍ គជ.ប.ជ. នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានអ្នកចូលរួមចំនួន **២៤**នាក់ ។<br>- កិច្ចប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការរវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការដៃគូក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងពិធីប្រគល់ លិខិតថ្លែងអំណរគុណ ដល់សមាគម **អង្គការជាតិចំនួន ៥៦** និងក្រុមហ៊ុនចំនួន ៤ លើកិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សអស់រយៈពេល ៥ឆ្នាំកន្លងមក ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅភោជនីយដ្ឋានទន្លេបាសាក់២ ភ្នំពេញ។<br>- កិច្ចពិភាក្សា និងការចែករំលែកបទពិសោធន៍ការងារ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ និង តំណាងអង្គការ IJM Cambodia ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ ជ.ប.ជ.អ្នកចូលរួមចំនួន ០៤នាក់។<br>- អមដំណើរលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានអ្នកចូលរួមចំនួន **១៨៣**នាក់ ស្រី ៦០នាក់។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សា ស្តីពីកិច្ចការពារជនរងគ្រោះ និងការអនុវត្តច្បាប់ ជាមួយអង្គការចាប់ដៃ អ្នកចូលរួមចំនួន០៨នាក់ ស្រី០២នាក់ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការត្រួតពិនិត្យការងាររបាយការណ៍ឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ ដើម្បីត្រៀមធ្វើសន្និបាទរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ |

| | |
|---|---|
| | ▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអនុវត្តៈ**<br>(១)លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ៥៩ច្បាប់ លិខិតចូល ២៩ច្បាប់។ (២)លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ៣៧ច្បាប់ លិខិតចូល ៣០ច្បាប់។(៣)រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។ (៤)បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ ខែមករា កុម្ភៈ និងខែមីនាឆ្នាំ២០២០ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។(៥)ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥ ជារៀងរាល់ខែ។(៦)រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។(៧)ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី។(៨)ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។<br>(៩)Scan & Uploaded ឯកសារចូលក្នុងបណ្ណាសារនៃប្រព័ន្ធ wiki បានចំនួន ២៣ច្បាប់។(១០)អាប់ឡូតរូបភាពសកម្មភាព គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធអ៊ិនធើណេត wiki បានចំនួន ៥៥សកម្មភាព។<br>▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ុន រ៉ូ** អគ្គលេខាធិការរង<br>○ បានអញ្ជើញចូលរួមជាគណៈអធិបតី នៃកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយខ្លឹមសារសៀវភៅគោល ស្តីពីលំហាត់របៀបសម្រាប់មន្ត្រីនគរបាលជាតិកម្ពុជា ក្រោមអធីបតីភាពឯកឧត្តម នាយឧត្តមសេនីយ៍ សាស្ត្រាចារ្យបណ្ឌិត **សេង ផល្លា** ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា។<br>○ បានដឹកនាំក្រុមជំនួយកិច្ចការងារបង្ការ ទប់ស្កាត់ ចូលរួមប្រជុំពិភាក្សាបន្ត ស្តីពីការបង្កើតមេរៀនប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើការបោះពុម្ពផ្សាយសាកល្បង ក្នុងការដាក់បញ្ចូលនៅក្នុងម៉ោងសិក្សាសង្គម ក្រោមអធិបតីភាព លោកជំទាវ **សឿ សុជាតា** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា នៅក្រសួងអប់រំ។<br>▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ៖**<br>- លោកប្រធានក្រុមបានចូលរួម៖<br>○ អមដំណើរ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍គជ នៃគណៈ.ប.ជ. កម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចុះសួរសុខទុក្ខនិង នាំយកថវិការជូនជនរងគ្រោះ សម្រាកព្យាបាលនៅមន្ទីរពេទ្យខេត្តកែបដោយគ្រោះថ្នាក់អាគាររលំបាក់ កាលពីថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០២០។<br>○ សហការជាមួយក្រសួងសង្គមកិច្ច និងអង្គការដៃគូរ បានចុះធ្វើការត្រួតពិនិត្យ តាមដានស្ត្រីពរពោះជំនួសចំនួន០៣នាក់នៅស្រុកស្រីសន្ធរ ស្រុកកងមាស និងស្រុកកោះសុទិន ខេត្ត កំពង់ចាម ។ |

○ ក្រុមការងារបានធ្វើការបូកសរុបរបាយការណ៍ឆ្នាំ ២០១៩ និងលើកទិសដៅបន្ត របស់ក្រុមកិច្ចការការពារជនរងគ្រោះ។

○ សិក្ខាសាលាថ្នាក់ជាតិស្តីពី កិច្ចការពារកុមារ ក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារភ្នំពេញ។

○ សិក្ខាសាលាផ្សព្វផ្សាយខ្លឹមសារសៀវភៅគោល ស្តីពីលំហាត់របៀបសម្រាប់មន្ត្រីនគរបាលជាតិ នៅសាលាបណ្ឌិត្យសភានគរបាលកម្ពុជា។

○ កិច្ចប្រជុំ ស្តីពីការលើកកម្ពស់សុវត្ថិភាពអ៊ីនធើណេតសីលធម៌សង្គម និងតម្លៃគ្រួសារខ្មែរ នៅសាលប្រជុំទីស្តីការ ក្រសួងអប់រំ យុវជន និងកីឡា។

○ កិច្ចប្រជុំក្រុមការងារអន្តរក្រសួង ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធើណេត (OCSE) នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។

▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់៖**

- ប្រធានក្រុមជំនួយកិច្ចការអនុវត្តច្បាប់បាន ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារក្នុងប្រព័ន្ធយុតិធម៌កម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **វង សូត** រដ្ឋមន្ត្រីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារភ្នំពេញ។

▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌៖**

- ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម វិរៈ** អគ្គលេខាធិការរង និងជាអ្នកនាំពាក្យ គ.ជ.ប.ជ បានអញ្ជើញចូលរួមពិធីជួបជុំរវាង **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងអ្នកសារព័ត៌មានក្នុងស្រុកលើកទី៤ នាថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័ណ៌ កោះពេជ្រ។

▪ **ក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិ៖**

- លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន ស៊ីរីលក្ខិណា** អគ្គលេខាធិការរង បានអញ្ជើញចូលរួម ៖

○ ចូលរួមកិច្ចប្រជុំពិភាក្សាក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ កិច្ចប្រជុំបានផ្តោតសំខាន់ទៅលើរបាយការណ៍យេនឌ័រឆ្នាំ២០១៩ និងរបាយការណ៍ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី។

○ ដឹកនាំក្រុមការងារប្រជុំផ្ទៃក្នុង ដើម្បីត្រួតពិនិត្យពីវឌ្ឍនភាពការងារ និងស្វែងរកបញ្ហាប្រឈម និងដំណោះស្រាយ អ្នកចូលរួមចំនួន០៦នាក់។

○ ចូលរួមកិច្ចប្រជុំពិភាក្សាអំពីគម្រោងកិច្ចសហការជាមួយតំណាងអង្គការ ASEAN-ACTS ដើម្បីសិក្សាពីតម្រូវការបន្ថែមអំពីផែនការ និងសកម្មភាពរបស់ក្រុមការងារសហប្រតិបត្តិការអន្តរជាតិដើម្បីឲ្យខាងអង្គការរៀបចំជាធនធាន ថវិកាដើម្បីធ្វើការចូលរួមសហការជាមួយគ្នា ក្នុងនោះដែរគេក៏បានបង្ហាញអំពីកញ្ចប់ថវិកាដៃគូមួយចំនួន ដែលគេមានសម្រាប់ប្រើប្រាស់ក្នុងឆ្នាំ២០២០។

○ ជាគណៈអធិបតីក្នុងសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការអនុវត្តគម្រោងចំណាកស្រុកឆ្លងដែន នៅសាលាស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ និងនៅខេត្តព្រះសីហនុ។

○ កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៩ និងលើកទិសដៅអនុវត្តឆ្នាំ២០២០ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។

○ កិច្ចប្រជុំអន្តរក្រសួងដើម្បីត្រៀមឯកសារចូលរួមកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា អ៊ីរ៉ុបលើកទី១១ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

| | |
|---|---|
| | ○ កិច្ចប្រជុំបូកសរុបរបាយការណ៍ ក្នុងពីធីបើកសន្និបាតត្រួតពិនិត្យការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ។<br>○ កិច្ចប្រជុំពិនិត្យ និងកែសម្រួលរបាយការណ៍ សម្រាប់ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ដើម្បីផ្ញើជូនក្រុមការងាររបាយការណ៍ នៃលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- លោកប្រធានក្រុម បានចូលរួមកិច្ចប្រជុំពិភាក្សា ជាមួយតំណាងអង្គការដៃគូចំនួន២គឺ អង្គការ LSCW និងGVC ស្តីពីកិច្ចសហការប្រមូលសេវាកម្មរបស់អង្គការដៃអភិវឌ្ឍន៍ដើម្បីដាក់បញ្ចូលទៅក្នុងប្រព័ន្ធ Database និងធ្វើការពិភាក្សាទៅលើការប្រមូលទិន្នន័យទាក់ទងនៅនឹងការរំលោភបំពានទៅលើជនទេសន្តរប្រវេសន៍ ដែលគេធ្វើនៅលើខេត្តគោលដៅចំនួនពីរគឺសៀមរាប និងបន្ទាយមានជ័យ។<br>- លោកអនុប្រធានក្រុម បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង លើការរៀបចំផែនការដកស្រង់ព័ត៌មានពលករវិលត្រឡប់រក្សាទុកក្នុង database ការរៀបចំផែនការក្រុមការងារ និងត្រួតពិនិត្យការងារពីដើមឆ្នាំ២០២០ ដើម្បីធ្វើការដកស្រង់ វិភាគ និងវាយតម្លៃការងារដែលបានធ្វើកន្លងមក ដែលមានអ្នកចូលរួមចំនួន ០៤នាក់។<br>- បានចូលរួមកិច្ចប្រជុំពិភាក្សា ត្រួតពិនិត្យរបាយការណ៍ឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អ្នកចូលរួមចំនួន១៥នាក់។ |
| ក្រសួងសង្គមកិច្ច អតីតយុវជន និង កីឡា | - **ឯកឧត្តម ញ៉ឹក ចណ្ណារ៉ា** រដ្ឋលេខាធិការក្រសួង ស.អ.យ បានដឹកនាំក្រុមការងារចូលរួមកិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងក្រុមការងារខេមមីត ។<br>- បានចូលរួមសិក្ខាសាលា ស្តីពីនីតិវិធីប្រតិបត្តិស្តង់ដាអន្តរទំនាក់ទំនង និងផែនការយថាភាពក្នុងកិច្ចសហប្រតិបត្តិការ នៃការត្រៀមលក្ខណៈឆ្លើយតប និងការវិលត្រឡប់ដោយជនចំណាកស្រុក នៅភោជនីយដ្ឋានទន្លេបាសក់ II ។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្រីព្រាងកម្មវិធីបណ្តុះបណ្តាលតាម Online ស្តីពីការសង្គ្រោះបឋមផ្នែកផ្លូវចិត្ត របស់អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (MOI) នៅភោជនីយដ្ឋានទន្លេបាសក់ II ។<br>- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីគោលនយោបាយទេសន្តរប្រវេសន៍ការងារឆ្នាំ២០១៩-២០២៣ នៅខេត្តសៀមរាប។<br>- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលកាលវិភាគស្ថានភាពដំបូង ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធអនឡាញនៅកម្ពុជា |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៧៣លើក អ្នកចូលរួមសរុបចំនួន ១.៨៣៣នាក់ (ស្រី ១.០១២នាក់)** | |
| ខេត្តកោះកុង | - ឯកឧត្តម ផាន់ ចាន់ធុល អភិបាលនៃគណៈអភិបាលខេត្តៈ<br>○ បានជួបពិភាក្សាការងារជាមួយអភិបាលខេត្តច័ន្ទបុរី ប្រទេសថៃ ដើម្បីសម្របសម្រួលដំណើរការចេញ ចូល ទាំងមនុស្ស និងទំនិញ នៅតាមច្រកព្រំដែន។<br>○ សហការជាមួយកម្លាំងនគរបាលប៉ុស្តិ៍ និងស្ថាប័នពាក់ព័ន្ធ ចុះត្រួតពិនិត្យការវិលត្រឡប់របស់ពលករខ្មែរតាមច្រកព្រំដែនអន្តរជាតិព្រំ និងច្រករបៀង(តាមអូរ តាមព្រៃ...)។ |

| | |
|---|---|
| **ខេត្តឧត្តរមានជ័យ** | - បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគោះយោបល់លើកិច្ចការស្ត្រី និងកុមារ ចំនួន០១លើក អ្នកចូលរួមចំនួន២២នាក់ ស្រី១១នាក់។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលចំនួន០២លើកគឺៈ<br>○ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ អ្នកចូលរួមចំនួន៤១នាក់ ស្រី៣៤នាក់<br>○ ស្តីពីការអភិវឌ្ឍន៍សហគ្រិនជាស្ត្រី អ្នកចូលរួមចំនួន៤២នាក់ ស្រី៤០នាក់។ |
| **ខេត្តសៀមរាប** | - លេខាធិការដ្ឋាន គ.ខ.ប.ជៈ<br>○ សហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) ចុះជួបសំណេះសំណាលជាមួយអតីតពលករ ពលការិនី និងក្រុមគ្រួសារ ដើម្បីប្រមូលព័ត៌មាន និងស្វែងយល់បញ្ហាបន្ថែមពីករណីជួញដូរកម្លាំងពលកម្ម និងកំណត់ពីតម្រូវការរបស់ជនរងគ្រោះទាក់ទងនឹងផ្នែកច្បាប់ សេវាសង្គមកិច្ច នៅស្រុកអង្គរជុំ ស្រុកក្រឡាញ់ និងស្រុកពួក។<br>○ បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារបច្ចេកទេស រួមមានក្រុមការងារបង្ការ ទប់ស្កាត់ ក្រុមការងារអនុវត្តច្បាប់ ក្រុមការងារការពារជនរងគ្រោះ និងក្រុមការងារកិច្ចការទេសន្តប្រវេសន៍ ស្តីពីការចុះត្រួតពិនិត្យលើមណ្ឌលរបស់អង្គការជារ៉ូម៉ា ក្នុងខេត្តសៀមរាប ចំនួន០១លើក។<br>○ បានរៀបចំកិច្ចប្រជុំ ស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែកុម្ភៈ និងលើកទិសដៅអនុវត្តខែមីនា ឆ្នាំ២០២០ ចំនួន០១លើក អ្នកចូលរួលចំនួន៥៦នាក់ ស្រី៣២នាក់។<br>○ ថ្នាក់ ស្រុកបានរៀបចំកិច្ចប្រជុំប្រចាំខែ ត្រីមាស ចំនួន០៣លើក អ្នកចូលរួមចំនួន ៧៨នាក់ ស្រី២១នាក់។<br>- រដ្ឋបាលស្រុកវ៉ារិន បានរៀបចំកិច្ចប្រជុំក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ស្រុក ចំនួន០១លើក អ្នកចូលរួមចំនួន៤៣នាក់ ស្រី០៤នាក់។ |
| **ខេត្តកណ្តាល** | - គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ២០១៩ និងលើកទិសដៅបន្ត ឆ្នាំ២០២០ ប្រចាំខែ និងប្រចាំត្រីមាសទី១ ឆ្នាំ២០២០ ក្រោមអធិបតីភាព លោកជំទាវ **ហ៊ុន កុសនី** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ មានអ្នកចូលរួមសរុប ចំនួន ២១៩នាក់ ស្រី១០៥នាក់ និងបានធ្វើរបាយការណ៍ជូន គ.ជ.ប.ជ។<br>- ក្រុមការងារក្រុង-ស្រុកទាំង១១ បានរៀបចំប្រជុំប្រចាំខែ បានចំនួន ៣០លើក/២៦លើក សរុបអ្នកចូលរួមចំនួន ៧១៨នាក់/៦៣១នាក់ ស្រី ៤៨២នាក់/៣៣៥នាក់ និងបានធ្វើរបាយការណ៍ប្រចាំខែជូនគ.ខ.ប.ជ ។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន០៩លើក អ្នកចូលរួមចំនួន ២០៤នាក់ ស្រី ១៣៣នាក់។ |
| **ខេត្តតាកែវ** | - លោកស្រីអនុប្រធានអចិន្ត្រៃយ៍ លេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារ ០១លើក នៅស្រុកអង្គរបុរី មានអ្នកចូលរួម ៥០នាក់ ស្រី០៨នាក់។<br>- រដ្ឋបាលឃុំរមេញ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហិង្សាក្នុងគ្រួសារចំនួន០១លើក អ្នកចូលរួមចំនួន២០៦នាក់ ស្រី៥០នាក់។ |

| | |
|---|---|
| | - លោកស្រីអនុប្រធានអចិន្ត្រៃយ៍ខេត្ត បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើហឹង្សាក្នុងគ្រួសារចំនួន០១លើក អ្នកចូលរួមចំនួន ៥៨នាក់ ស្រី ០៣នាក់។ |
| ខេត្តស្វាយរៀង | - លេខាធិការដ្ឋាន គ.ខ.ប.ជ<br>○ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០ អ្នកចូលរួមចំនួន២៤៣នាក់ ស្រី៣៨នាក់។<br>- បានបញ្ជូនមន្ត្រីនគរបាលចំនួន០៥នាក់ ស្រី០២នាក់ ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងបច្ចេកទេសសម្ភាសជនរងគ្រោះដោយអំពើហឹង្សាទាក់ទងនឹងយេនឌ័យ និងការជួញដូរមនុស្ស នៅខេត្តក្រចេះ។ |
| ខេត្តបាត់ដំបង | - លេខាធិការដ្ឋាន សហការជាមួយអង្គការ និងមន្ទីរសង្គមកិច្ច ស្វែងរកសាច់ញ្ញាតិរបស់ពលកររងគ្រោះមានផ្ទៃពោះ និងសតិមិនសូវល្អដែលត្រឡប់មកពីប្រទេសថៃ ឱ្យបានត្រឡប់ទៅស្រុកកំណើតនៅខេត្តតាកែវ។<br>- មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមធ្វើបទបង្ហាញស្តីពីស្ថានភាពចំណាកស្រុក និងគោលនយោបាយគាំពារពលរដ្ឋចំណាកស្រុកក្នុងកម្មវិធីវេទិកាសហគមន៍ស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការប្រឆាំងការជួញដូរមនុស្ស នៅសាលាស្រុកកំរៀង។ |
| ខេត្តកំពង់ឆ្នាំង | - ក្រុមការងារក្រុង-ស្រុក បានប្រជុំប្រចាំខែមករា ដើម្បីត្រួតពិនិត្យការអនុវត្តការងារ។<br>- គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត(គ.ខ.ប.ជ) បានរៀបចំកិច្ចប្រជុំលទ្ធផលការងារប្រុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែមករា កុម្ភៈ មីនា និងប្រចាំត្រីមាសទី១ ឆ្នាំ២០២០ ដែលមានការអញ្ជើញចូលរួមពីក្រុមទាំង៦ និងបណ្តាក្រុង/ស្រុកទាំង៨។<br>- បានរៀបចំកិច្ចប្រជុំលទ្ធផលការងារប្រុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែមីនា ត្រីមាសទី១ និងលើកទិសដៅការងារអនុវត្តបន្ត។<br>- គ.ខ.ប.ជ បានចុះត្រួតពិនិត្យ និងចាត់វិធានការវេជ្ជសាស្ត្រ ចំពោះពលកយចំណាកស្រុកទៅក្រៅប្រទេសដែលត្រឡប់មកស្រុកកំណើតវិញ ចំនួន៥២នាក់។ |
| ខេត្តកំពង់ស្ពឺ | - គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត(គ.ខ.ប.ជ) បានរៀបចំ<br>○ កិច្ចប្រជុំបូកសរុបរបាយការណ៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆ្នាំ២០១៩ ទិសដៅ២០២០ អ្នកចូលរួមចំនួន ៧៥នាក់ ស្រី២៩នាក់។<br>○ សន្និបាតបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០ អ្នកចូលរួម ចំនួន៤៦៣នាក់ ស្រី១៩៧នាក់។<br>○ បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី និងក្មេងស្រី ០១លើក នៅមន្ទីរកិច្ចការនារីខេត្ត អ្នកចូលរួម ៣៤នាក់ ស្រី២៨នាក់។ |
| ខេត្តព្រះសីហនុ | - លោកស្រីកិបាលរង និងជាប្រធានលេខាធិការដ្ឋាន ព្រមទាំងក្រុមការងារ និងអង្គការយែរកម្ពុជា បានជួបពិភាក្សារកស្រុកគោលដៅដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយទប់ស្កាត់ការចំណាកស្រុកដោយសុវត្ថិភាព អំពើហិង្សាក្នុងគ្រួសារ និងអំពើជួញដូរមនុស្ស។ |

| | |
|---|---|
| **ខេត្តកំពង់ធំ** | - ក្រុមការងារជំនាញបានចូលរួមប្រជុំពិភាក្សាស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារប្រចាំឆ្នាំ២០១៩ ក្រោមអធិបតីភាព **លោកជំទាវនាយឧត្តមសេនីយ៍ អគ្គស្នងការរងនគរបាលជាតិ** នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។<br>- បានចូលរួមប្រជុំបូកសរុបលទ្ធផលការងារ ក្រុមការងារជាតិកម្ពុជាដើម្បីស្ត្រី ប្រចាំឆ្នាំ២០១៩ និងលើកផែនការឆ្នាំ២០២០ នៅវិមានសន្តិភាព រាជធានីភ្នំពេញ។<br>- បានចូលរួមកិច្ចប្រជុំ និងជំរុញដល់សមាជិក គ.ក.ស.ក និងក្រុមប្រឹក្សាឃុំជាស្ត្រី ដែលមានភារកិច្ចត្រូវចុះទៅតាមបណ្តាភូមិ ឃុំ ដើម្បីផ្សព្វផ្សាយការងារពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស នៅសាលាស្រុកប្រាសាទបល្ល័ង្គ អ្នកចូលរួមចំនួន២៧នាក់ ស្រី២៥នាក់។ |
| **ខេត្តកំពង់ចាម** | - បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការសង្គ្រោះបឋមផ្នែកផ្លូវចិត្ត របស់អង្គការ IOM នៅសណ្ឋាគារ អិល ប៊ី អិន ខេត្តកំពង់ចាម។<br>- បានចូលរួមពិធីផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមកិច្ច នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>- បានចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការសង្គ្រោះបឋមផ្នែកផ្លូវចិត្ត របស់អង្គការ IOM នៅសណ្ឋាគារ អិល ប៊ី អិន ខេត្តកំពង់ចាម។<br>- បានចូលរួមពិធីផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមកិច្ច នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ |
| **ខេត្តក្រចេះ** | - បានរៀបចំកិច្ចប្រជុំ ស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែកុម្ភៈ និងលើកទិសដៅខែមីនា ឆ្នាំ២០២០ អ្នកចូលរួមចំនួន៤៨នាក់ ស្រី១២នាក់។ |
| **ខេត្តស្ទឹងត្រែង** | - បានចាត់កម្លាំងជំនាញចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការសម្ភាសន៍ និងកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស រយៈ៥ថ្ងៃ នៅខេត្តក្រចេះ។ |
| **ខេត្តកោះកុង** | - លោកស្រី សុខ សុជាវី ប្រធានមន្ទីរកិច្ចការនារី និងជាអនុប្រធានលេខាធិការដ្ឋានខេត្តៈ<br>○ បានជួបពិភាក្សាការងារជាមួយតំណាងស្ថានទូតអាមេរិកប្រចាំកម្ពុជា និងតំណាងអង្គការវីនរ៉ក់អន្តរជាតិ ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួម ១៤នាក់(ស្រី ០៤នាក់)។<br>○ បានចុះជួបពលករខ្មែរដែលថៃចាប់បញ្ជូនតាមច្រកព្រំដែនអន្តរជាតិចាំយាម ចំនួន០៤នាក់ បានអប់រំណែនាំ និងផ្តល់ថវិកាមួយចំនួន។ |